# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

មហាអយ្យការ ប្រចាំ
សាលាឧទ្ធរណ៍ ភ្នំពេញ
លេខ ៤០០/៩៧

## អគ្គរដ្ឋអាជ្ញា ប្រចាំសាលាឧទ្ធរណ៍ភ្នំពេញ

**ជម្រាបមក**

**លោក ប្រធានតុលាការខេត្តស្វាយរៀង**

**សូមជ្រាប។**

**កម្មវត្ថុ:** ការផ្តល់យោបល់អំពីករណីនគរបាលដោះលែងជនអន្តោប្រវេសន៍ ។

**យោង:** លិខិតរបស់លោក លេខ ២១២ អ.ក ចុះថ្ងៃទី០១-០៨-៩៧ ។

តាមលិខិតរាយការណ៍យោងខាងលើ លោកបានទទួលដំណឹងថា នគរបាលខេត្តស្វាយរៀងចាប់បានជនអន្តោប្រវេសន៍ ចិនដីគោកចំនួន៤នាក់ រថយន្តមួយគ្រឿង នឹងអ្នកបើកបរម្នាក់ កាលពីថ្ងៃទី១៩-០៧-០៩៧ ប៉ុន្តែលោកស្នងការនគរបាលខេត្តបានដោះលែងទៅវិញទាំងអស់ដោយគ្មានបញ្ជូនខ្លួនជនល្មើស វត្ថុតាង និងកំណត់ហេតុមកអយ្យការសោះ ។

ខ្ញុំសូមជម្រាបលោកវិញថា តាមបញ្ញត្តិមាត្រា ៣៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌថ្ងៃទី២៨ ខែមករា ឆ្នាំ ១៩៩៣ ស្នងការនគរបាល អធិការនគរបាល ឬប្រធាន ឬនាយការិយាល័យនគរបាលខេត្ត កាលណាបំពេញតួនាទីដើម្បីពិនិត្យស្រាវជ្រាវអំពើល្មើស និងបទល្មើសព្រហ្មទណ្ឌណាមួយទាំងបទល្មើសព្រហ្មទណ្ឌចែងក្នុងមាត្រា ២៩,៣២ នៃព្រះរាជក្រមលេខ ០៥ន.ស-៩៤ ចុះថ្ងៃទី២២-០៩-៩៤ នោះ គាត់បំពេញតួនាទីជាមន្ត្រីនគរបាលយុត្តិធម៌ ហើយស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់ព្រះរាជអាជ្ញា ប៉ុន្តែពុំមែនក្រោមក្រឡាបញ្ជីទេ ។ ដូច្នេះលោកព្រះរាជអាជ្ញាក្នុងនាមជាអ្នកត្រូវចេញបញ្ជាផ្ទាល់ លោកអាចចាត់ការតាមន័យនេះតទៅ ។ បើលោកចាត់ការហើយ ។យល់ឃើញថា គ្មានការគោរពបញ្ជារបៀបណាមួយលោកអាចរាយការណ៍ទៅឯកឧត្តមអភិបាលខេត្ត ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ និងមកខ្ញុំអគ្គព្រះរាជអាជ្ញាប្រចាំសាលាឧទ្ធរណ៍ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៩៧

**អគ្គរដ្ឋអាជ្ញា**

**ហង់រ៉ូ រ៉ាគេន**

<u>ចម្លងជូន</u>

-ក្រសួងយុត្តិធម៌ ដើម្បីជ្រាប